# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីនិន្នាការសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ីខាងកើត ក្នុងត្រីមាសទី២ ឆ្នាំ២០០៩ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

ក្នុងត្រីមាសទី២ ឆ្នាំ២០០៩ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅសហរដ្ឋអាមេរិកមានអត្រា -៣,៩% ធៀបនឹង ២,៨% ក្នុងត្រីមាសទី២ ឆ្នាំ២០០៨ ។ ការធ្លាក់ចុះគួរឱ្យកត់សម្គាល់នេះ បណ្ដាលជាសំខាន់ពីការរួមចំណែកអវិជ្ជមាន នៃវិនិយោគលើសារពើភ័ណ្ឌឯកជន ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន និងការនាំចេញ ប៉ុន្តែមានការប៉ះប៉ូវមួយផ្នែកវិញ ដោយការរួមចំណែកវិជ្ជមាននៃចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ និងចំណាយរបស់រដ្ឋ និងរដ្ឋបាលមូលដ្ឋាន ។ ក្នុងត្រីមាសនេះដែរ កំណើនផលិតផលពិតប្រចាំឆ្នាំនៅតំបន់អឺរ៉ូ មានអត្រា -៤,៨% ហើយមូលហេតុចំបងនៃការធ្លាក់ចុះនេះ គឺការធ្លាក់ចុះខ្លាំងនៃការបង្កើតទ្រព្យមូលធនជាប់លាប់ដុល (-១១,៤%) និងការនាំចេញ (-១៧,៧%) ប៉ុន្តែមានការប៉ះប៉ូវវិញ ដោយសារកំណើនចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល ២,៥% ធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន ។ កំណើន ផសស ពិត នៅជប៉ុន កើនឡើងវិញដល់ ០,៦% បន្ទាប់ពីបានរួមចុះ ៩,១% នៅត្រីមាសមុន ហើយកត្តាសំខាន់អាចជា ការរើបឡើងវិញនៃការនាំចេញ ការបញ្ជាទិញគ្រឿងចក្រ និងផលិតផលឧស្សាហកម្ម ។

កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅចិន ឡើងខ្ពស់ដល់ ៧,៩% ធៀបនឹង ៦,១% នៅត្រីមាសទី១ ឆ្នាំ២០០៩ ដោយសារកំណើនខ្លាំងក្នុងវិស័យសេវាកម្ម និងកម្មន្តសាល ។ ការរើបសេដ្ឋកិច្ចអាចមើលឃើញច្បាស់នៅហុងកុង ក្នុងត្រីមាសទី២ ដោយ ផសស ពិត មានអត្រាកំណើន -៣,៨% ធៀបនឹង -៧,៨% នៅត្រីមាសមុន ។ ការរើបឡើងវិញនេះ បណ្ដាលពីចំណាយប្រើប្រាស់ដែលបានល្អប្រសើរឡើង ប៉ុន្តែវាមានល្បឿនយឺត ដោយសារចំណាយវិនិយោគមានតិចតួច និងបានធ្លាក់ចុះ ១៤% ធៀបនឹងកាលពីមួយឆ្នាំមុន។ នៅកូរ៉េខាងត្បូងក៏មាននិន្នាការប្រហាក់ប្រហែលគ្នា ដោយចំណាយជាមូលធនបានក្លាយជាវិជ្ជមានវិញ ហើយការនាំចេញទំនិញកើន ១៤% ធៀបនឹងត្រីមាសមុន ។ ផសស ពិត នៅតៃវ៉ាន់ បានធ្លាក់ចុះនៅត្រីមាសទី២ ឆ្នាំ២០០៩ ប៉ុន្តែមិនធ្ងន់ធ្ងរដូចក្នុងត្រីមាសទី១ ទេ ហើយការប្រសើរឡើងបន្តិចម្ដងៗនេះ បណ្ដាលជាសំខាន់ ដោយសារចំណាយប្រើប្រាស់ក្នុងស្រុកកាន់តែមានច្រើន និងកំណើនលឿននៃការនាំចេញទំនិញ និងសេវា ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ទិន្នន័យ ផសស នៅម៉ាឡេស៊ី បង្ហាញពីស្ថានភាពសេដ្ឋកិច្ចដែលមានស្ថិរភាពឡើងវិញ និងអត្រារួមចុះពីមួយឆ្នាំទៅមួយឆ្នាំមានកំរិតទាបជាងនៅត្រីមាសមុន ដែលបណ្ដាលជាសំខាន់ដោយសារការនាំចេញទំនិញ និងសេវាកម្មមានកំណើនខ្លាំង (៥,៤%) និងកំណើនការបង្កើតទ្រព្យមូលធនជាប់លាប់ (៩,៧%) ។ នៅត្រីមាសទី២ នេះ សេដ្ឋកិច្ចរបស់ ថៃ និងសិង្ហបុរី ក៏មានសញ្ញារើបឡើងវិញខ្លះៗដែរ ។ កំណើន ផសស ពិត ពីមួយឆ្នាំទៅមួយឆ្នាំនៅសិង្ហបុរី គឺ -៣,៥% ដោយសារ ចំណាយប្រើប្រាស់ឯកជន ចំណាយវិនិយោគសហគ្រាស និងការនាំចេញសុទ្ធនូវទំនិញ និងសេវា បានល្អប្រសើរឡើង ។ នៅត្រីមាសទី២ ថៃមានការរួមចុះសេដ្ឋកិច្ចយឺតជាងមុន ដោយសារការធ្លាក់ចុះយឺតជាងមុន នៃចំណាយប្រើប្រាស់ក្នុងគ្រួសារ និងចំណាយវិនិយោគ និងការរួមចំណែកវិជ្ជមានយ៉ាងតូចមួយរបស់រដ្ឋាភិបាលនៅក្នុងចំណាយប្រើប្រាស់។

## អតិផរណាក្នុងពិភពលោក និងអត្រាការប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០០៩ នៅប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួន និងប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងតំបន់ ជាពិសេសអាស៊ាន មានការបារម្ភកាន់តែច្រើនអំពីសំពាធបរិត្តផរណា ។ ថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិកបន្តធ្លាក់ចុះ (-០,៩%) នៅត្រីមាសទី២ ។ តម្រូវការក្នុងស្រុកដែលធ្លាក់ចុះធ្ងន់ធ្ងរ ដោយសារសេដ្ឋកិច្ចធ្លាក់ចុះ បានធ្វើឱ្យទំនិញជាទូទៅធ្លាក់ថ្លៃខ្លាំងនៅសហរដ្ឋអាមេរិក ។ នៅត្រីមាសដដែល ថ្លៃទំនិញប្រើប្រាស់ជាទូទៅនៅតំបន់អឺរ៉ូ នៅថេរ ដោយសារប្រេង និងផលិតផលផ្សេងៗធ្លាក់ថ្លៃ ។ អតិផរណាថ្លៃទំនិញប្រើប្រាស់នៅជប៉ុនធ្លាក់ចុះដល់ -១,០% នៅពេលសេដ្ឋកិច្ចរើបឡើងវិញ ។ បរិត្តផរណានេះអាចមកពីសេដ្ឋកិច្ចធ្លាក់ចុះធ្ងន់ធ្ងរ និងកំណើនគម្លាតក្នុងផលិតកម្ម ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ប្រាក់ដុល្លារUS ឡើងថ្លៃទល់នឹងប្រាក់យ៉េនជប៉ុន ដោយប្ដូរបាន ៩៥,៩៥យ៉េន/ដុល្លារUS ប៉ុន្តែធ្លាក់ថ្លៃទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង ដុល្លារតៃវ៉ាន់ និងប្រាក់អឺរ៉ូ ដោយប្ដូរបាន ១២៧៣,៩វ៉ុន/ដុល្លារUS ៣៣,១ដុល្លារតៃវ៉ាន់/ដុល្លារUS និង ០,៧១អឺរ៉ូ/ដុល្លារUS ។ នៅត្រីមាសដដែល ប្រាក់ដុល្លារ US នៅថេរធៀបនឹងប្រាក់យ៉ុនចិន និងដុល្លារហុងកុង ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី២ នេះ ក៏មានការធ្លាក់ថ្លៃទំនិញកសិកម្មមួយចំនួនគួរឱ្យកត់សម្គាល់ ។ ពោត (US No.2) អង្ករ (Thai 100% B) និងសណ្ដែកសៀង (US No.1) ធ្លាក់ថ្លៃ ៦,៥% ៤,៣% និង ៣,៣% រៀងគ្នា ធៀបនឹងត្រីមាសមុន ប៉ុន្តែប្រេងឆាឡើងថ្លៃ ១៣% ។ នៅទីផ្សារទំនិញថាមពល ប្រេងឆៅ សាំង និងម៉ាស៊ូតឡើងថ្លៃ ៣៥,៧% ៣៤,៨% និង ១៨,៥% រៀងគ្នា ធៀបនឹងត្រីមាសមុន ។

*រៀបរៀងដោយ សាំង ច័ន្ទហង្ស*

# តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 6.4 | 6.1 | 5.2 | 4.4 | 3.9 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | 6.3 | 4.7 | 0.1 | -6.2 | -3.9 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | 1.9 | -0.6 | -4.2 | -10.1 | -3.5 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | 5.3 | 3.9 | -4.3 | -7.1 | -4.9 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 10.1 | 9.0 | 6.8 | 6.1 | 7.9 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | 4.2 | 1.7 | -2.5 | -7.8 | -3.8 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 4.8 | 3.8 | -3.6 | -4.4 | -2.2 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | 4.3 | -1.0 | -8.4 | -10.2 | -7.5 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | 1.4 | 0.6 | -1.3 | -2.5 | -4.8 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | 1.0 | -0.5 | -4.6 | -9.1 | 0.6 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | 2.8 | -0.5 | -6.3 | -2.6 | -3.9 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 24.9 | 21.7 | 15.7 | 4.3 | -4.8 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 10.1 | 11.9 | 11.4 | 8.5 | 5.6 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 4.8 | 8.4 | 5.9 | 3.7 | 1.3 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 7.5 | 6.5 | 5.5 | 2.1 | -0.5 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | 7.7 | 7.2 | 2.2 | -0.2 | -2.8 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 24.4 | 29.0 | 23.6 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 7.8 | 5.3 | 2.5 | -0.6 | 1.5 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 5.7 | 4.6 | 2.3 | 1.7 | -0.1 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 4.8 | 5.5 | 4.5 | 3.9 | 2.8 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 4.2 | 4.5 | 1.9 | 0.0 | -0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 3.8 | 3.8 | 2.3 | 1.0 | 0.9 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | 1.4 | 2.2 | 1.0 | -0.1 | -1.0 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | 4.4 | 5.3 | 1.5 | -0.2 | -0.9 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.3 | 4092.5 | 4103.2 | 4062.7 | 4054.2 | 4030.3 | 4117.4 | 4089.8 | 4108.0 | 4128.55 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938 | 9705 | 9134 | 9419 | 9699.0 | 9,265.3 | 9,216.3 | 11,060 | 11,630.8 | 10,225.0 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.79 | 3.67 | 3.31 | 3.34 | 3.21 | 3.37 | 3.56 | 3.63 | 3.52 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.37 | 1.43 | 1.49 | 1.51 | 1.45 |
| ថៃ (បាត) | 40.2 | 40.2 | 37.9 | 32.22 | 33.36 | 32.25 | 34.0 | 34.83 | 35.29 | 33.98 |
| វៀតណាម (ដុង) | 15,777 | 15,859 | 15,994 | 16,030 | 16,382 | 16,881 | 16,517 | 16,537 | 16,954 | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ួន) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.96 | 6.82 | 6.83 | 6.84 | 6.83 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.8 | 7.78 | 7.80 | 7.77 | 7.75 | 7.75 | 7.75 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145 | 1024 | 955 | 929.04 | 1137.23 | 1018.84 | 1207.0 | 1,367.2 | 1,412.5 | 1,273.9 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.6 | 32.1 | 32.5 | 32.85 | 31.54 | 30.45 | 31.20 | 33.0 | 34.0 | 33.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.7 | 0.84 | 0.64 | 0.71 | 1.32 | 0.76 | 0.71 |
| ជប៉ុន (យ៉េន) | 108.2 | 110.2 | 116.4 | 117.8 | 102.46 | 104.53 | 104.03 | 96.1 | 93.72 | 95.95 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - US ($/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 238.03 | 254.99 | 181.22 | 183.12 | 171.16 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 1086.89 | 949.03 | 564.50 | 636.53 | 719.35 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 839.58 | 657.88 | 519.41 | 522.13 | 499.45 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 479.97 | 529.30 | 382.72 | 434.40 | 420.10 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 33.5 | 50.14 | 61.58 | 69.25 | 95.44 | 117.48 | 115.30 | 55.23 | 42.34 | 57.46 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.9 | 42.19 | 47.70 | 53.58 | 62.22 | 80.90 | 81.27 | 34.52 | 31.97 | 43.11 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.2 | 95.37 | 88.46 | 46.98 | 34.17 | 40.51 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

អនុមតិគំរោងវិនិយោគ បានធ្លាក់ចុះអស់ ៣ត្រីមាស បន្តបន្ទាប់ ។ នៅត្រីមាសទី២ ឆ្នាំ២០០៩ អនុមតិគំរោងវិនិយោគធ្លាក់ចុះយ៉ាងខ្លាំងអស់ ៩៦% មកត្រឹម ៣៩,៤លានដុល្លារអាមេរិក ដោយសារការធ្លាក់ចុះខ្លាំងនៃអនុមតិគំរោងវិនិយោគលើវិស័យទាំង៣ គឺ កសិកម្ម (ពី ១៧៥,៣លានដុល្លារ កាលពីត្រីមាសមុនមកដល់សូន្យ) សេវាកម្ម (ពី ៤៩៥,៦លានដុល្លារ មកដល់សូន្យ) និងឧស្សាហកម្ម (ធ្លាក់ចុះ ៨៤%) ។ ផ្ទុយទៅវិញ អនុវិស័យកាត់ដេរមានកំណើនខ្លាំង ពី ១៦៤លានដុល្លារ កាលពីត្រីមាសមុន ដល់ ៣៥,០លានដុល្លារ ដែលប្រហែលមកពីរដ្ឋាភិបាលបានផ្អាកការយកពន្ធដារលើឧស្សាហកម្មកាត់ដេរ ។ ត្រូវបានអនុម័តដែរនូវគម្រោងស្រាវជ្រាវខាងរ៉ែ និងគម្រោងសាងសង់រោងចក្រថាមពលជីវម៉ាស ដែលមានតំលៃស្មើនឹង ១១% នៃតំលៃអនុមតិគម្រោងសរុបក្នុងវិស័យឧស្សាហកម្ម ។

តំលៃអនុមតិគំរោងសាងសង់នៅរាជធានីភ្នំពេញ បានបន្តធ្លាក់ចុះខ្លាំងចាប់ពីត្រីមាសទី៤ ឆ្នាំ២០០៨ ។ នៅត្រីមាសទី២ ឆ្នាំ២០០៩ អនុមតិគំរោងសាងសង់សរុប ធ្លាក់ចុះ ៦៦% មកត្រឹម ៦២,៣លានដុល្លារ បើធៀបនឹងត្រីមាសមុន ។ អនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះ ២១% មកត្រឹម ៦,៧លានដុល្លារ ហើយអនុមតិគំរោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ៨០% មកត្រឹម ១៨,៩លានដុល្លារ ។ ធៀបនឹងត្រីមាសទី២ ឆ្នាំ២០០៨ អនុមតិគំរោងសាងសង់សរុប ធ្លាក់ចុះ ៥៦% ក្នុងនោះអនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ ធ្លាក់ចុះ ៦២% និងអនុមតិគំរោងសាងសង់ផ្ទះល្វែង ធ្លាក់ចុះ ៦៦% ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ចំនួនភ្ញៀវបរទេសមកដល់កម្ពុជា ធ្លាក់ចុះ ២៥% ធៀបនឹងត្រីមាសមុន មកត្រឹម ៤៦៤.២៣០នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាស ធ្លាក់ចុះ ៣៤% មកត្រឹម ២២១.២២១នាក់ ក្នុងនោះអាកាសយានដ្ឋានភ្នំពេញទទួលបានអ្នកដំណើរ ៥១% និងអាកាសយានដ្ឋានសៀមរាបទទួលបាន ៤៩% ។ ភ្ញៀវមកដល់តាមផ្លូវគោក ធ្លាក់ចុះ ៨,៥% មកត្រឹម ២៣២.១៦៦នាក់ ហើយភ្ញៀវមកដល់តាមផ្លូវទឹក ធ្លាក់ចុះ ៦៧% មកត្រឹម ១០.៨៤៣នាក់ ។ ភ្ញៀវមកសំរាកលំហែ ធ្លាក់ចុះ ២៩% មកត្រឹម ៣៨៩.៧៣៨នាក់ រីឯភ្ញៀវមកធ្វើជំនួញ ធ្លាក់ចុះ ១,៧% មកត្រឹម ៣៣.១៣២នាក់ ។ ការធ្លាក់ចុះសេដ្ឋកិច្ចពិភពលោក គឺជាកត្តាចំបងនាំឱ្យមានការធ្លាក់ចុះចំនួនភ្ញៀវមកដល់ប្រទេសកម្ពុជា ។ ឆ្លើយតបនឹងបញ្ហានេះ រដ្ឋាភិបាលកំពុងប្រឹងប្រែងទាក់ទាញភ្ញៀវទេសចរ មកពីបណ្តាប្រទេសដែលរងឥទ្ធិពលតិចពីវិបត្តិសេដ្ឋកិច្ចសាកល (រួមមាន វៀតណាម ថៃ និងឡាវ) តាមរយៈការធ្វើកំណែទំរង់នីតិវិធីចេញចូល ដើម្បីសម្រួលដល់ភ្ញៀវទាំងនោះ ។ នីតិវិធីថ្មីនេះ អនុញ្ញាតឱ្យភ្ញៀវទេសចរមកពីប្រទេសខាងលើ ប្រើប្រាស់លិខិតបើកផ្លូវ ដើម្បីចូលមកទស្សនាកំសាន្ត និងស្នាក់នៅក្នុងប្រទេសកម្ពុជា បានរយៈពេលមួយសប្តាហ៍ ដែលកាលពីមុនបានត្រឹមបីថ្ងៃប៉ុណ្ណោះ ។ ជាលទ្ធផលនៃការសម្រួលនិតិវិធីនេះ ចំនួនភ្ញៀវទេសចរវៀតណាមមកដល់កម្ពុជាបានកើនឡើង ៤,២% រហូតដល់ ៧៥.៣៩៧នាក់ ហើយភ្ញៀវទេសចរឡាវ កើន ១៣% ដល់ ២៧.៩០៧នាក់ ប៉ុន្តែភ្ញៀវទេសចរថៃ ធ្លាក់ចុះ ៧,៥% មកត្រឹម ២៤.៤៤៦នាក់ ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ឱនភាពពាណិជ្ជកម្មមានសភាពកាន់តែអាក្រក់ដោយឡើងដល់ ៦២៧,៣លានដុល្លារ ធៀបនឹង ១៥៧,៦លានដុល្លារ នៅត្រីមាសមុន ។ ការធ្លាក់ចុះនេះ បណ្តាលមកពីការនាំចេញធ្លាក់ចុះខ្លាំង ខណៈពេលដែលការនាំចូលកើនឡើងតិចតួច ។ ធៀបនឹងត្រីមាសមុន ការនាំចេញសរុប ធ្លាក់ចុះ ៤០% មកត្រឹម ៤៣៣,៥លានដុល្លារ ដោយសារការនាំចេញសំលៀកបំពាក់ ត្រី និងកៅស៊ូ ធ្លាក់ចុះ ។ ការនាំចេញសំលៀកបំពាក់ ធ្លាក់ចុះ ៣៨% មកត្រឹម ៣៧៧,៣លានដុល្លារ ឯការនាំចេញត្រី ធ្លាក់ចុះ ១៥% មកត្រឹម ០,៧លានដុល្លារ ហើយការនាំចេញកៅស៊ូ ធ្លាក់ចុះ ៣០% មកត្រឹម ៨,២លានដុល្លារ ។ ផ្ទុយទៅវិញ ការនាំចេញឈើបានកើនពី ០,០៥លានដុល្លារ រហូតដល់ ០,១លានដុល្លារ ។

នៅត្រីមាសទី២ នេះដែរ តំលៃការនាំចូលកើនឡើង ៧,៤% រហូតដល់ ១០៦០,៨លានដុល្លារ ។ ការនាំចូលផលិតផលប្រេងកាត កើន ៧,២% រហូតដល់ ៧២,២លានដុល្លារ ប៉ុន្តែការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ២៥% មកត្រឹម ៣០,៩លានដុល្លារ ក្នុងនោះការនាំចូលស៊ីម៉ង់ត៍ ធ្លាក់ចុះ ១៥% មកត្រឹម ៩,២លានដុល្លារ និងដែកថែប ធ្លាក់ចុះ ៤៣% មកត្រឹម ១២,៥លានដុល្លារ ។ ការនាំចូលវាយនភ័ណ្ឌ ធ្លាក់ចុះ ៦៧% មកត្រឹម ១៧,៩លានដុល្លារ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ឆ្នាំ២០០៩ ឱនភាពថវិកា បានថយចុះ ៦,៥% មកត្រឹម ៥១៣,៤ពាន់លានរៀល ដោយមានកំណើនទាំងផ្នែកចំណូល និងផ្នែកចំណាយ ។ ប្រាក់ចំណូលប្រមូលបាន កើន ១៤% ដល់ ១២៥២,៧ពាន់លានរៀល ក្នុងនោះចំណូលពន្ធ កើន ១៦% ដល់ ១០៩៦,៥ពាន់លានរៀល តែត្រូវប៉ះប៉ូវនឹងចំណូលមិនមែនពន្ធ ដែលធ្លាក់ចុះ ០,៧% មកត្រឹម ១៤៩,២ពាន់លានរៀល ។ ពន្ធក្នុងស្រុក មាន ៧៦% នៃចំណូលពន្ធសរុប ឬកើន ១៨% ធៀបនឹងត្រីមាសមុន ។ ពន្ធលើពាណិជ្ជកម្មអន្តរជាតិ កើន ៩,៦% ដល់ ២៥៧,៨ពាន់លានរៀល ។ ក្នុងចំណូលមិនមែនពន្ធ ចំណូលបានពីអចលនទ្រព្យ ធ្លាក់ចុះ ២៦% មកត្រឹម ៩,៧ពាន់លានរៀល រីឯការលក់ទំនិញ និងសេវាកើន ៧,៩% ដល់ ១០០,៩ពាន់លានរៀល ។ ទន្ទឹមនឹងនេះ ចំណូលមូលធនកើន ៧៤% ដល់ ៧,០ពាន់លានរៀល ។

នៅត្រីមាសទី២ ចំណាយសរុប កើន ៧,០% ធៀបនឹងត្រីមាសមុន ដល់ ១៧៦៦,១ពាន់លានរៀល ។ ចំណាយចរន្ត កើន ៤២% ដល់ ១០៦៤,៧ពាន់លានរៀល ប៉ុន្តែត្រូវបានប៉ះប៉ូវខ្លះវិញ ដោយការថយចុះចំណាយមូលធន ១៣% មកត្រឹម ៦០៧,១ពាន់លានរៀល ។ ចំណាយលើបៀវត្សរ៍ កើន ៥៨% ដល់ ៥១៥,៩ពាន់លានរៀល ស្របពេលដែលចំណាយឧបត្ថម្ភធន និងជំនួយឧបត្ថម្ភសង្គម ធ្លាក់ចុះ ១៥% មកត្រឹម ១៨៥,៩ពាន់លានរៀល ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## អតិផរណា និងអត្រាប្ដូរប្រាក់

នៅរាជធានីភ្នំពេញ ក្នុងត្រីមាសទី២ ឆ្នាំ២០០៩ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅ ធ្លាក់ចុះ ៤,៨% ពីមួយឆ្នាំទៅមួយឆ្នាំ។ អាហារ និងភេសជ្ជៈគ្មានជាតិស្រា ធ្លាក់ថ្លៃ ៥,២% ។ ថ្លៃស្នាក់នៅ និងទឹកភ្លើង ថយចុះ ៩,៣% ថ្លៃដឹកជញ្ជូន ថយ ១៦,៥% ហើយថ្លៃទូរគមនាគមន៍ ថយ ១០,១% ។ ចំណែកឯ ថ្លៃសំលៀកបំពាក់ និងគ្រឿងសំរាប់ពាក់នៅជើង កើន ៥,១% ថ្លៃសង្ហារឹម និងប្រតិបត្តិការក្នុងផ្ទះ កើន ៥,៦% ថ្លៃថែទាំសុខភាពកើន ៣,៧% ថ្លៃសកម្មភាពលំហែកំសាន្ត កើន ០,៩% និងថ្លៃអប់រំកើន ២៦,១% ។

នៅត្រីមាសទី២ ឆ្នាំ២០០៩ ប្រាក់រៀលប្ដូរបាន ៤១២៨,៦រៀល/ដុល្លារ US ឬធ្លាក់ថ្លៃ ២,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ប្រាក់រៀលឡើងថ្លៃ ៤,៩% ទល់នឹងប្រាក់បាតថៃ ដោយប្ដូរបាន ១១៩,២រៀល/បាត និងឡើងថ្លៃ ៦,៣% ទល់នឹងប្រាក់ដុងវៀតណាម ដោយប្ដូរបាន ២៣,៣រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែមិថុនា ២០០៩ រូបិយវត្ថុទូទៅ (M2) កើន ៩,១% ដល់ ១៣.៨៥៩,៦ពាន់លានរៀល ធៀបនឹងខែដូចគ្នាឆ្នាំមុន ។ ប្រាក់រៀលចរាចរកើន ១១% ដល់ ២៦០៣,៦ពាន់លានរៀល ។ បញ្ញើជាប្រាក់រៀលកើន ២៥% ដល់ ៣៣៤,៤ពាន់លានរៀល ហើយបញ្ញើជាដុល្លារកើន ៨,៣% ដល់ ១០.៩២១,៦ពាន់លានរៀល ។

ក្នុងអំឡុងខែមិថុនា នេះដែរ តាមការកាត់កងគ្នារវាងឥណទានសុទ្ធដល់រដ្ឋាភិបាល និងឥណទានដល់វិស័យឯកជន គេឃើញថាទ្រព្យសកម្មក្នុងស្រុក កើនបាន ១១% ដល់ ៧២៤០,៦ពាន់លានរៀល ។ ឥណទានសុទ្ធដល់រដ្ឋាភិបាលថយចុះមកត្រឹម -២៨៨៨,៩ពាន់លានរៀល ដោយសារបញ្ញើរបស់រដ្ឋាភិបាលកើនឡើង ៧,១% ដល់ ៣១៥៩,៤ពាន់លានរៀល ខណៈពេលដែលឥណទានស្ថិតនៅថេរត្រឹម ២៧០,៥ពាន់លានរៀល ។ ទន្ទឹមនឹងនេះ ឥណទានដល់វិស័យឯកជន កើន ៦,៧% ដល់ ១០.១២៩,៦ពាន់លានរៀល ។ បំណុលផ្សេងៗ កើន ១៦% ដល់ ៥៩៩១,៩ពាន់លានរៀល ដែលធ្វើឱ្យទ្រព្យសកម្មក្នុងស្រុកសុទ្ធថយចុះ៧,២% មកត្រឹម១២៤៨,៧ពាន់លានរៀល ។ ផ្ទុយទៅវិញ ទ្រព្យសកម្មបរទេសសុទ្ធ កើន ១១% ដល់ ១២.៦១០,៩ ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

អង្កេតលើពលករងាយរងគ្រោះក្នុងខែសីហា ២០០៩ បង្ហាញថាប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពួកគេ បានធ្លាក់ចុះ ៨,៩% ធៀបនឹងខែឧសភា ២០០៩ ប៉ុន្តែបានកើន ២,៧% បើធៀបនឹងខែកុម្ភៈ ឆ្នាំដដែល ។

នៅខែសីហា ២០០៩ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ១១,៣% បើធៀបនឹងខែឧសភា ដោយធ្លាក់ពី ៨៨៩៦រៀល/ថ្ងៃ មកត្រឹម ៧៦៩២រៀល/ថ្ងៃ ។ អ្នកធាក់ស៊ីក្លូ ៨០,៦% បានប្រាប់ថា ពួកគេមិនសូវមានការងារធ្វើច្រើនដូចកាលពីប៉ុន្មានខែមុនឡើយ ជាពិសេសនៅពេលដែលចំនួនអ្នករត់ម៉ូតូឌុបបានកើនឡើង ។ អ្នកធាក់ស៊ីក្លូភាគច្រើនជាអ្នកធ្វើចំណាកស្រុកមកពីទីជនបទ ក្នុងនោះមាន ៣២,៥% បានចាកចេញមកដោយសារមិនអាចរកការងារធ្វើបាននៅក្នុងភូមិ, ២៥% ចាកចេញមកដោយសារមានជីវភាពគ្រួសារក្រីក្រ, ២២,៥% ធ្វើចំណាកស្រុក តាមរដូវកាល និង ២០% ទៀត ចាកចេញដោយសារគិតថានៅទីក្រុងសំបូរការងារធ្វើជាង ។

នៅខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ថយចុះ ១៩,៧% ធៀបនឹងខែឧសភា គឺធ្លាក់ចុះពី ១២.១៤៨រៀល/ថ្ងៃ មកត្រឹម ៩៧៥៩រៀល/ថ្ងៃ ។ ក្នុងអំឡុងពេលបីខែមុននេះ ពួកគេមិនសូវមានឱកាសច្រើន ដើម្បីរកប្រាក់ឡើយ ហើយក្នុងនោះមាន ៧៧,៥% អាចរកប្រាក់បានត្រឹមគ្រប់គ្រាន់ល្មមសំរាប់ខ្លួនឯងប៉ុណ្ណោះ ។ អ្នករត់ម៉ូតូឌុបឆ្លើយសម្ភាសន៍ ៥២,៥% ប្រាប់ថាពួកគេបានទៅខ្ចីបុលអ្នកដទៃ ដើម្បីដោះស្រាយជីវភាពនៅពេលប្រាក់ចំណូលធ្លាក់ចុះនេះ ។

នៅខែសីហានេះដែរ ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់មានជំនាញ ធ្លាក់ចុះ ១១,២% ធៀបនឹងខែឧសភា មកត្រឹម ១២.១៥៥រៀល ។ ប៉ុន្តែបើធៀបនឹងខែកុម្ភៈ ប្រាក់ចំណូលរបស់ពួកគេកើនឡើង ៣,៣% ។ ការថយចុះនៃប្រាក់ចំណូលនេះ បណ្ដាលមកពីកំណើនការប្រកួតប្រជែងរវាងកម្មករ ។ កម្មករសំណង់ភាគច្រើន (៦៥%) ប្រាប់ថា ពួកគេស្នាក់នៅក្នុងការដ្ឋានសំណង់ ហើយ ១៧,៥% ស្នាក់នៅផ្ទះជួល និង ១០% ស្នាក់នៅផ្ទះរបស់ខ្លួនឯង រីឯ ៧,៥% ទៀត ស្នាក់នៅជាមួយសាច់ញាតិ ឬនៅវត្ត ។ ពួកគេចំណាយប្រហែល ៣៦៥០រៀល/ថ្ងៃ លើម្ហូបអាហារ ឬចំណាយតិចជាងមុន ៤,៣% បើធៀបនឹងខែឧសភា ។

នៅខែសីហា ២០០៩ ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាច ធ្លាក់ចុះ ១៣,១% បើធៀបនឹងខែឧសភា ឆ្នាំដដែល មកត្រឹម ៨៤៨៩រៀល ។ មានអ្នកលក់បន្លែដែលបានសម្ភាសតែ ១០% ប៉ុណ្ណោះដែលប្រាប់ថា ប្រាក់ចំណូលប្រចាំថ្ងៃរបស់ខ្លួនកើនឡើង ខណៈពេលដែលអ្នកលក់បន្លែ ៩០% ទៀត ឆ្លើយថាប្រាក់ចំណូលប្រចាំថ្ងៃរបស់ខ្លួនមាននិន្នាការផ្ទុយពីនេះ ។អ្នកលក់បន្លែភាគច្រើនបានឱ្យដឹងថា ការថយចុះប្រាក់ចំណូលបណ្ដាលមកពីកំណើនការប្រកួតប្រជែងក្នុងអាជីវកម្មនេះ ដែលធ្វើឱ្យអាជីវករ ៣០% ក្លាយជាអ្នកជាប់បំណុលគេ ។ អាជីវករ ៧០% ប្រាប់ថា កង្វះដើមទុនវិនិយោគ គឺជាកត្តាមួយដែលនាំឱ្យប្រាក់ចំណូលធ្លាក់ចុះ ។

នៅខែសីហា ២០០៩ ប្រាក់ចំណូលរបស់អ្នករើសអេតចាយ កើន ៨,៩% បើធៀបនឹងខែឧសភា ។ អ្នកផ្ដល់សម្ភាសន៍ ៩៧,៥% ប្រាប់ថា មូលហេតុចំបងនៃកំណើននេះ គឺរបស់អេតចាយបានឡើងថ្លៃ ។ អ្នករើសអេតចាយភាគច្រើន ត្អូញត្អែរពីបញ្ហាចំងាយផ្លូវឆ្ងាយជាងមុនទៅដល់កន្លែងចាក់សំរាមនៅជើងឯក ដែលធ្វើឱ្យពួកគេត្រូវចំណាយពេលវេលា និងសោហ៊ុយច្រើនជាងមុន ដើម្បីទៅប្រមូលរបស់អេតចាយនៅទីនោះ ។ ពួកគេត្រូវចំណាយប្រាក់ ៣០០០រៀល/ថ្ងៃ សំរាប់ថ្លៃដឹកជញ្ជូន ហើយនេះជាតួលេខចំណាយធំមួយ បើធៀបនឹងចំណូលប្រចាំថ្ងៃរបស់ពួកគេ ។ អ្នករើសអេតចាយ ៨៥% ប្រាប់ថា ពួកគេត្រូវប្រើប្រាក់ចំណូលរបស់ខ្លួន ដើម្បីជួលផ្ទះស្នាក់នៅ ។

*រៀបរៀងដោយ*

*ផាន់ ដាលីស និង ប៊ុន ដូរីណា*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 12.0 | 102.4 | 52.3 | 16.7 | 18.6 | 4.4 | 175.3 | 0.0 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 187.2 | 328.0 | 52.9 | 95.0 | 91.6 | 485.4 | 257.7 | 39.4 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *40.7* | *69.1* | *42.3* | *47.8* | *31.3* | *21.4* | *16.4* | *35.0* |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 957.7 | 311.1 | 148.2 | 4064.9 | 4450.5 | 1339.6 | 495.6 | 0.0 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *653.8* | *199.2* | *93.7* | *4015.0* | *3481.3* | *1168.1* | *254.1* | *0.0* |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 1156.9 | 741.5 | 253.4 | 4176.5 | 4560.7 | 1580.3 | 928.6 | 39.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 504.7 | -35.9 | -78.1 | 1548.2 | 9.2 | -65.3 | -41.2 | -95.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | 334.6 | -23.7 | -49.1 | 2083.2 | 294.2 | 113.1 | 266.5 | -99.0 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និង ផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 21.7 | 20.2 | 45.3 | 17.6 | 52.1 | 39.7 | 32.1 | 6.7 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 117.5 | 57.6 | 40.9 | 55.1 | 65.6 | 60.0 | 95.2 | 18.9 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 40.6 | 94.3 | 51.2 | 68.2 | 369.3 | 252.2 | 53.7 | 36.7 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 179.7 | 172.2 | 137.3 | 140.9 | 486.9 | 351.9 | 181.1 | 62.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 24.2 | -4.2 | -1.4 | 2.6 | 245.6 | -27.7 | -48.5 | -65.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 88.2 | 120.2 | -1.4 | -2.6 | 170.9 | 104.4 | 31.9 | -55.8 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 278.5 | 368.8 | 402.0 | 262.0 | 259.2 | 316.2 | 335.2 | 221.2 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 153.3 | 239.2 | 242.2 | 192.0 | 186.3 | 261.4 | 287.1 | 243.0 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 431.8 | 608.0 | 644.2 | 454.0 | 445.5 | 577.6 | 622.3 | 464.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | 1.7 | 40.8 | 6.0 | -29.5 | -1.9 | 29.6 | 7.7 | -25.4 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 16.5 | 17.8 | 17.0 | 6.9 | 3.2 | -5.0 | -3.4 | 2.2 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 1708.1 | 2108.1 | 2352.8 | 2799.9 | 890.8 | 793.4 | 803.1 | 539.6 | 928.7 | 728.6 | 721.4 | 433.5 |
| ក្នុងនេះ: សំលៀកបំពាក់ | 1628.4 | 2027 | 2253.3 | 2698.9 | 846.1 | 727.1 | 773.4 | 463.8 | 868.8 | 678.8 | 606.9 | 377.3 |
| កៅស៊ូ | 35.1 | 38.3 | 36.7 | 41.4 | 11.7 | 14.6 | 7.0 | 11.0 | 12.9 | 5.2 | 11.8 | 8.2 |
| ឈើ | 10.2 | 11.1 | 10.3 | 8.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.1 | 0.1 |
| ត្រី | 2.8 | 10.6 | 10.1 | 5.9 | 1.2 | 0.9 | 0.7 | 0.3 | 0.6 | 0.6 | 0.9 | 0.7 |
| ការនាំចូលសរុប | 1824.9 | 2149.0 | 2513.0 | 3057.0 | 924.5 | 982.7 | 983.8 | 1178.5 | 1027.1 | 916.3 | 987.7 | 1060.8 |
| ក្នុងនេះ: ផលិតផលប្រេងកាត | 191.6 | 187.0 | 184.8 | 238.5 | 71.0 | 58.9 | 60.0 | 64.6 | 68.3 | 62.9 | 67.3 | 72.2 |
| សំភារៈសំណង់ | 80.8 | 95.3 | 134.7 | 154.4 | 34.9 | 32.5 | 39.7 | 40.7 | 35.6 | 29.9 | 41.4 | 30.9 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245.0 | 2731.0 | 818.6 | 891.3 | 884.1 | 1073.2 | 923.2 | 823.5 | 879.0 | 957.7 |
| ជញ្ជីងពាណិជ្ជកម្ម | -116.8 | -40.9 | -160.1 | -257.1 | -30.7 | -189.3 | -180.7 | -638.9 | -98.4 | -187.7 | -157.6 | -627.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | 22.9 | -14.1 | 6.4 | -40.0 | 87.3 | -21.9 | -10.5 | -37.8 |
| ការនាំចេញសរុប | - | - | - | - | 26.4 | -10.9 | 1.2 | -32.8 | 72.1 | -21.5 | -0.9 | -39.9 |
| ការនាំចូលសរុប | - | - | - | - | 1.4 | 6.3 | 0.1 | 19.8 | -12.8 | -10.8 | 7.8 | 7.4 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -54.1 | -64.9 | 291.4 | 19.8 | 8.2 | 1.6 | 14.2 | -32.6 | 2.7 | -6.6 | -21.5 | -18.6 |
| ការនាំចេញសរុប | 17.5 | 23.4 | 11.6 | 19.0 | 10.3 | 7.7 | 13.5 | -23.5 | 4.3 | -8.2 | -10.2 | -19.7 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | 21.6 | 17.9 | 21.7 | 24.4 | 29.3 | 11.1 | -6.8 | 0.4 | -9.9 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by National Bank of Cambodia*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៣-០៩ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 1764 | 2126 | 2625 | 3259.2 | 1031.4 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 | 1101.7 | 1252.7 |
| ចំណូលចរន្ត | 1733 | 2107 | 2474 | 2881.8 | 1031.4 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 | 1097.7 | 1245.7 |
| ចំណូលពន្ធ | 1220 | 1577 | 1911 | 2270.9 | 844.6 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 | 947.4 | 1096.5 |
| ពន្ធក្នុងស្រុក | - | - | - | - | 584.8 | 661.8 | 719.9 | 955.5 | 776.7 | 796.3 | 712.0 | 838.7 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 259.8 | 303.5 | 258.1 | 299.5 | 294.5 | 309.4 | 235.4 | 257.8 |
| ចំណូលមិនមែនពន្ធ | 513 | 530 | 563 | 610.9 | 186.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 | 150.3 | 149.2 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 14.8 | 13.6 | 2.9 | 53.9 | 11.0 | 10.2 | 13.1 | 9.7 |
| លក់ទំនិញ និងសេវា | - | - | - | - | 100.1 | 124.3 | 118.9 | 96.3 | 99.7 | 109.8 | 93.5 | 100.9 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 72.0 | 38.5 | 89.6 | 41.9 | 106.4 | 60.3 | 43.7 | 38.6 |
| ចំណូលជាមូលធន | 31 | 19 | 152 | 377.4 | 0.0 | 4.5 | 4.8 | 16.5 | 8.7 | 49.3 | 4.0 | 7.0 |
| ចំណាយសរុប | 2757 | 2932 | 3295 | 4174.7 | 1126.1 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 | 1650.6 | 1766.1 |
| ចំណាយជាមូលធន | 1171 | 1163 | 1328 | 1638.1 | 355.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 | 693.6 | 607.1 |
| ចំណាយចរន្ត | 1586 | 1769 | 1967 | 2536.8 | 771.0 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 | 752.4 | 1064.7 |
| បៀវត្សរ៍ | 615 | 640 | 711 | 822.0 | 253.4 | 362.6 | 250.7 | 367.0 | 363.6 | 415.7 | 327.4 | 515.5 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 115.0 | 194.2 | 104.3 | 325.7 | 111.9 | 385.2 | 217.3 | 185.9 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 402.6 | 325.5 | 193.1 | 403.8 | 442.6 | 345.4 | 207.7 | 363.2 |
| សមតុល្យជាទូទៅ | -993 | -806 | -706 | -915.6 | -78.7 | -543.6 | 135.0 | -281.1 | -365.8 | -495.9 | -548.9 | -513.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886 | 864 | 1127 | 1360.7 | 290.3 | 741.5 | 299.2 | 615.8 | 435.0 | 705.1 | 507.8 | 326.7 |
| ហិរញ្ញប្បទានក្នុងស្រុក | 106 | 148 | -396 | -445.1 | -148.0 | -185.8 | -294.1 | -236.5 | 234.7 | 168.9 | -310.3 | 236.5 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (ខែតុលា-ធ្នូ ២០០៦:១០០) | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | - | - | - | - | 7.7 | 12.3 | 20.6 | 33.3 | 28.7 | 17.8 | 4.3 | -4.8 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | 12.8 | 18.9 | 29.5 | 47.6 | 37.4 | 24.1 | 6.1 | -5.2 |
| - ដឹកជញ្ជូន | - | - | - | - | 2.3 | 9.6 | 21.7 | 28.9 | 27.8 | 4.1 | -13.0 | -16.5 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4082.3 | 4030.1 | 3995.3 | 4030.2 | 4117.5 | 4089.8 | 4111.6 | 4128.6 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 130.0 | 129.3 | 129.1 | 125.4 | 121.9 | 117.7 | 116.6 | 119.2 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 25.3 | 25.2 | 25.2 | 24.9 | 24.8 | 24.3 | 23.6 | 23.3 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 80.8 | 94.4 | 111.6 | 107.7 | 106.0 | 98.2 | 105.6 | 110.7 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1508 | 2088 | 2633 | 3140 | 3203 | 3679 | 3982 | 4975 | 5495 | 3768.9 | 2873.7 | 3056.9 |
| ថ្លៃសាំង (រៀល/លីត្រ) | 2150 | 2833 | 3442 | 4004 | 4002 | 4368 | 4580 | 5171 | 5391 | 3861.3 | 3112.6 | 3452.4 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-០៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4,027 | 4,797 | 5,475 | 7,224 | 9,768 | 10,735 | 10,911 | 11,353 | 10,809 | 10,345 | 11,222 | 12,611 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698 | -467 | -450 | -282 | 140 | 576 | 1,136 | 1,345 | 1,748 | 15,13.3 | 1,266 | 1,249 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128 | -209 | -421 | -953 | -1,547 | -1,816 | -2,400 | -2,678 | -2,653 | -2,987 | -3,048 | -2,889 |
| ឥណទានដល់ផ្នែកឯកជន | 1,337 | 1,817 | 2,394 | 3,630 | 5,376 | 6,386 | 8,050 | 9,206 | 9,781 | 9,894 | 9,814 | 10,129 |
| រូបិយវត្ថុទូទៅ M2 | 3,329 | 4,330 | 5,025 | 6,942 | 9,908 | 11,311 | 12,047 | 12,698 | 12,557 | 11,858 | 12,488 | 13,859 |
| រូបិយវត្ថុ M1 | 937 | 1,153 | 1,323 | 1,658 | 1,750 | 2,052 | 2,389 | 2,467 | 2,335 | 2,399 | 2,545 | 2,695 |
| រូបិយវត្ថុផ្សេងៗ | 2,392 | 3,177 | 3,702 | 5,285 | 8,158 | 9,259 | 9,658 | 10,231 | 10,223 | 9,459 | 9,942 | 11,164 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 53.4 | 62.9 | 54.5 | 43.1 | 26.7 | 4.8 | 3.7 | 9.1 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 12.0 | 23.8 | 33.2 | 41.1 | 33.4 | 16.9 | 6.5 | 9.2 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 66.5 | 75.2 | 61.0 | 43.5 | 25.3 | 2.2 | 2.9 | 9.1 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2004 | 2005 | 2006 | 2007 | 2007 | 2008 | 2009 | | | 2009 | | |
| | | | | | វិច្ឆិកា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7,618 | 8,085 | 7,469 | 8,075 | 9,675 | 12,628 | 8,534 | 8,896 | 7,892 | -32.4 | 4.0 | -11.0 |
| អ្នកលីសែង | 6,925 | 6,734 | 6,545 | 8,588 | 9,119 | 9,005 | 10,476 | 10,319 | 8,321 | 16.0 | -2.0 | -19.0 |
| អ្នកលក់បន្លែតូចតាច | 6,953 | 7,739 | 6,390 | 8,220 | 8,552 | 9,926 | 7,614 | 9,764 | 8,489 | -23.0 | 28.0 | -13.0 |
| អ្នករើសអេតចាយ | 4,456 | 5,167 | 4,416 | 5,422 | 5,727 | 4,652 | 5,170 | 6,637 | 7,228 | 11.0 | 28.0 | 9.0 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4,439 | 4,344 | 4,412 | 4,482 | 4,643 | 4,327 | 4,283 | 4,346 | 4,665 | -1.0 | 1.0 | 7.0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4,233 | 4,370 | 5,306 | 5,516 | 6,426 | 8,697 | 7,044 | 7,126 | 5,900 | -19.0 | 1.0 | -17.0 |
| កម្មកររោងចក្រកាត់ដេរ | 8,048 | 7,359 | 7,649 | 7,568 | 7,240 | 6,554 | 6,754 | 6,691 | 7,558 | 3.0 | -1.0 | 13.0 |
| អ្នករត់ម៉ូតូឌុប | 9,259 | 10,595 | 8,201 | 10,634 | 11,872 | 15,691 | 11,655 | 12,148 | 9,759 | -26.0 | 4.0 | -20.0 |
| កម្មករសំណង់គ្មានជំនាញ | 6,391 | 6,712 | 5,918 | 6,155 | 7,777 | 8,779 | 6,115 | 9,956 | 9,632 | -30.0 | 63.0 | -3.0 |
| កម្មករសំណង់មានជំនាញ | 12,691 | 12,049 | 10,316 | 11,154 | 11,286 | 12,710 | 11,771 | 13,688 | 12,155 | -7.0 | 16.0 | -11.0 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*